# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ១៦៧

ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៣ **សាលដីកា**

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

លេខៈ ១៧០

ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២-លោក | វៀល | មួន | ជាចៅក្រម |
| ៣-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៤-លោក | ប៉ែន | សាររឿន | ជាចៅក្រម |
| ៥-លោក | យូរ | ឧត្តរា | ជាចៅក្រមរបាយការណ៍ |

**ក្រឡាបញ្ជី**

លោក អ៊ួ សុផុន

តំណាងមហាអយ្យការ

លោក **សាយ សាវី** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ២០៦"ឈ" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៧៥ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **អ៊ុំ ស្រ៊ុ** (ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅផ្ទះលេខ ៣២៥E₀ ផ្លូវលេខ៤៧០ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះអ៊ុំ សៀ "ស" ម្ដាយឈ្មោះឃឹម ឈាង "រ" ប្ដីឈ្មោះសេង ណិច មានកូន០៤នាក់ ។

ចុងចម្លើយឈ្មោះ **ឃឹម ឈាង** (ជាចុងបណ្ដឹងសាទុក្ខ) ភេទស្រី អាយុ៧២ឆ្នាំ ជាតិខ្មែរ មុខរបរជរា ទីលំនៅផ្ទះលេខ៣៥A ផ្លូវ៤៦៤ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ។ ឪពុកឈ្មោះឃឹម ម៉ង់ "ស" ម្ដាយឈ្មោះគីម ឈាវ "ស" ប្ដីឈ្មោះអ៊ុំ សៀ មានកូន០៧នាក់ ។

**កម្មវត្ថុបណ្ដឹង** : ប្ដឹងទាមទារចំណែកផ្ទះលេខ ៣៥A .

បានឃើញបណ្តឹងសាទុក្ខលេខ ៤៦៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះអ៊ីវ ស្រី ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២០៦"ឈ" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៦៧ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៦-៣-២០០២ របស់ឈ្មោះអ៊ីវ ស្រី ថា : ខ្លួនបានរស់នៅជាមួយម្តាយឈ្មោះឃឹម ណាង តាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ រហូតមកដល់បច្ចុប្បន្ន ។ ស្រាប់តែនៅថ្ងៃទី០២-១០-២០០១ ឈ្មោះឃឹម ឈាង ជាម្តាយបានដេញខ្លួនចុះចេញពីផ្ទះ ហើយមានបំណងលក់ផ្ទះនេះ ។ ក្នុងរឿងនេះ ខ្លួនសុំទាមទារមួយចំណែកនៃការលក់ផ្ទះខាងលើ និងសុំចូលស្នាក់នៅក្នុងផ្ទះដូចដើមវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៨"ឌ" ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះអ៊ីវ ស្រី ចុះថ្ងៃទី០៦-០៣-២០០២ និងការប្តឹងសុំនាពេលសវនាការនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-សំរេចឱ្យឈ្មោះអ៊ីវ ស្រី ភេទស្រី អាយុ៤០ឆ្នាំ ទីលំនៅផ្ទះលេខ ៣៥A ផ្លូវលេខ៤៦៤ ក្រុម៧ ភូមិ២ សង្កាត់ទួលទំពូង១ ខ័ណ្ឌចំការមនក្រុងភ្នំពេញ បានចូលមកស្នាក់នៅផ្ទះលេខ៣៥A ផ្លូវ៤៦៤ សង្កាត់ទួលទំពូង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញដូចដើមវិញគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៣-សំរេចឱ្យឈ្មោះឃឹម ឈាង ភេទស្រី អាយុ៧២ឆ្នាំ បង្កលក្ខណៈងាយស្រួលដល់ការចូលទៅស្នាក់នៅរបស់ឈ្មោះអ៊ីវ ស្រី ។ "ឈ្មោះអ៊ីវ ស្រី ភេទស្រី អាយុ៤០ឆ្នាំ និងឈ្មោះឃឹម ឈាង ភេទស្រី អាយុ៧២ឆ្នាំ ត្រូវជាម្តាយ និងកូនការ ដែលស្នាក់នៅជាមួយគ្នា ត្រូវគោរពសិទ្ធិគ្នា យោគយល់គ្នា រក្សាសាមគ្គីភាពរវាងគ្នា ក្នុងឋានៈជាពលរដ្ឋដ៏ល្អក្នុងសង្គម " ។

៤-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្លឹងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន៥.០០០រៀល សរុប៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចជាស្រេច កាលបើផុតកំណត់ឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួន ៧.០០០៛នេះ ឱ្យទៅដើមចោទវិញ ។

៥-សាលក្រមនេះ ជំនុំជំរះ ជាសាធារណៈចំពោះមុខដើមចោទ និង ចុងចម្លើយ សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១០"ឱ" ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះ ឃឹម ឈាង ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៨"ឱ" ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការរដ្ឋប្បវេណីលេខ២០៦"ឈ" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០១-៧-២០០២ របស់ឈ្មោះឃឹម ឈាង ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៨"ឱ" ចុះថ្ងៃទី២៦-៦-២០០២របស់ តុលាការក្រុងភ្នំពេញ ចោលជាអសាររបង់ ។

៣-ប្រគល់ផ្ទះទំនាស់លេខ ៣៥A ផ្លូវលេខ៤៦៤ សង្កាត់ទួលទំពូងទី១ ខណ្ឌ ចំការមន ក្រុងភ្នំពេញ ឱ្យទៅឈ្មោះឃឹម ឈាង កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វីង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ ។ នៅពេលដែលសាលដីកានេះ ចូលជាស្ថាពរបង្គាប់ឱ្យ ដើមចោទបង់ពន្ធសមាមាត្រ១% លើថ្លៃដីទំនាស់ ។ ប្រាក់ពន្ធសមាមាត្រនេះ ដាក់ចូលថវិការដ្ឋ៨០% និងត្រូវបានរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៥-សាលដីកានេះ ជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤-១១-២០០២ ចំពោះមុខ គូក្ដី និង ប្រកាសជាសាធារណៈ នៅថ្ងៃទី១៥-១១-២០០២ ចំពោះមុខគូក្ដី ។ បើកផ្លូវប្ដឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ៤៦៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះអ៊ីវ ស្រី ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២០៦"ឈ" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២របស់ សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០២ របស់ឈ្មោះអ៊ីវ ស្រី ។

បានឃើញសារណាបន្ថែមចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះអ៊ីវ ស្រី និង លោកមេធាវីសោម ច័ន្ទឌីណា ។

បានឃើញសារណាតបចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះឃឹម ឈាង ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលាឧទ្ធរណ៍សំរេចសេចក្ដី មកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះអ៊ីវ ស្រី នាពេលជំនុំជំរះថា ៖ ផ្ទះទំនាស់នេះ ខ្លួនបានចូលរស់នៅតាំងពីឆ្នាំ១៩៨១ នៅឆ្នាំ១៩៨៣ ខ្លួនរៀបការជាមួយឈ្មោះសេង ណិច ហើយរស់នៅលើផ្ទះនេះរហូតមក ដោយមានមុខរបរជាអ្នកធ្វើស្បែកជ្រូក និងដូរលុយ ហើយមានកូនចំនួន០៤នាក់។ ខ្លួនមានតួនាទីជាអ្នកចិញ្ចឹមម្តាយឪពុក ប្អូន២ និងកូនទៀតផង ។

សំណូមពរសុំចូលរស់នៅលើផ្ទះទំនាស់វិញ ។ និងសុំឱ្យតុលាការកំពូលបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោល ។

បានស្តាប់ចម្លើយរបស់ឈ្មោះឃឹម ឈាង នាពេលសវនាការថា ៖ ផ្ទះទំនាស់នេះ ឈ្មោះអ៊ីវ ស្រី ជាកូនទី២ បានប្រគល់ឱ្យខ្លួនជាកម្មសិទ្ធិតាំងពីឆ្នាំ១៩៨៣ មកម្ល៉េះ ។

សំណូមពរ សុំអោយតុលាការកំពូលតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី អ៊ីវ ស្រី ,ចម្លើយរបស់អ្នកស្រីឃឹម ឈាង
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៦៣ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២ របស់ឈ្មោះអ៊ីវ ស្រី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា អ្នកស្រីឃឹម ឈាង ដែលជាម្តាយបង្កើតរបស់អ្នកស្រីអ៊ីវ ស្រី បានកាន់កាប់គ្រប់គ្រងផ្ទះនេះ តាំងពីឆ្នាំ១៩៨១ រហូតដល់សព្វថ្ងៃក្នុងតួនាទីជាមេគ្រួសារ ។ ចំណែកឯឈ្មោះអ៊ីវ ស្រី ជាកូនក្នុងបន្ទុករបស់ម្តាយពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៨៤ បានរៀបការ ហើយចេញទៅរស់នៅផ្សេង ។ ក្រោយមកពេលឆ្នាំ១៩៩០ ខ្លួនមានផ្ទៃពោះ ទើបអ្នកស្រីឃឹម ឈាង ហៅមកនៅជាបណ្តោះអាសន្នជាមួយ ។

- យល់ឃើញថា ការដែលអ្នកស្រីអ៊ីវ ស្រី បានលើកឡើងនៅក្នុងសារណារបស់ខ្លួនចុះថ្ងៃទី២៦-០៥-២០០៣ ថា ខ្លួនបានរស់នៅតាំងពីឆ្នាំ១៩៨១ តំណាលគ្នាជាមួយនឹងម្តាយរបស់នាងដែរនោះ គឺជាការពិតហើយ ប៉ុន្តែខ្លួនរស់នៅក្នុងបន្ទុករបស់ម្តាយ ។ ដូច្នេះម្តាយជាអ្នកមានសិទ្ធិលើផ្ទះទំនាស់នេះ។រីឯការលើកឡើងថា ខ្លួនបានជួសជុលសាងសង់ផ្ទះនេះ ក៏ពុំមានភស្តុតាងអ្វីបញ្ជាក់ដែរ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២០៦"ឈ"ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខតុក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ៤៦៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះអ៊ីវស្រ៊ី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ២០៦"ឈ" ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រដែលដើមចោទ បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្វឹងចំនួន ៤.០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រ សរុប ១៩.០០០រៀល

បង្គាប់ឱ្យដើមចោទ បង់ពន្ធសមាមាត្រ១%នៃតំលៃផ្ទះទំនាស់

៤-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤ ។